ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# វឌ្ឍនៈ
# សម្រាប់រយៈពេល ៣ ឆ្នាំ
# (កក្កដា ២០១៩ - មិថុនា ២០២២)

សហគមន៍នេសាទ ៖ វឌ្ឍនៈ
ភូមិ ៖ វឌ្ឍនៈ
ឃុំ ៖ វឌ្ឍនៈ
ស្រុក ៖ សំបូរ
ខេត្ត ៖ ក្រចេះ

ខែមករា ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# វឌ្ឍនៈ
# សម្រាប់រយៈពេល ៣ ឆ្នាំ
# ( កក្កដា ២០១៩ - មិថុនា ២០២២ )

14

សហគមន៍នេសាទ ៖ វឌ្ឍនៈ

ភូមិ ៖ វឌ្ឍនៈ

ឃុំ ៖ វឌ្ឍនៈ

ស្រុក ៖ សំបូរ

ខេត្ត ៖ ក្រចេះ

ខែមករា ឆ្នាំ២០១៩

# មាតិកា


១. ស្ថានភាពទូទៅ ........ ១

២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ........ ២

ក. ប្រជាពលរដ្ឋ ........ ២

ខ. មុខរបរ ........ ២

៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ ........ ២

ក. ទីតាំង ........ ២

ខ. ដែននេសាទ ........ ៣

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៣

ឃ. ធនធានជលផល ........ ៣

៤. ការធ្វើនេសាទ ........ ៣

ក. អ្នកនេសាទ ........ ៣

ខ. ឧបករណ៍នេសាទ ........ ៤

គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........ ៤

៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៥

ក. ទស្សនៈវិស័យ ........ ៥

ខ. គោលបំណងរួម ........ ៥

គ. គោលបំណងជាក់លាក់ ........ ៥

ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៥

ឃ.១. ធនធានជលផល និងអេកូឡូស៊ី ........ ៥

ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ ........ ៧

ឃ.៣. ការគ្រប់គ្រង ........ ៨

ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........ ១១

ច. យុទ្ធសាស្ត្រ ........ ១២

តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ភូមិខ្សាច់លាវរយៈពេល ៣ ឆ្នាំ (២០១៩-២០២២) ........ ១៣

តារាងកម្មវិធីការងារប្រចាំឆ្នាំ (កក្កដា ២០១៩ - មិថុនា ២០២២) ........ ១៩

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទវត្ថុរ្លនៈ មានទីតាំងស្ថិតនៅក្នុងភូមិវត្ថុរ្លនៈ ឃុំវត្ថុរ្លនៈ ស្រុកសំបូរ ខេត្តក្រចេះ។ សហគមន៍នេសាទនេះ បានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រវាងខណ្ឌរដ្ឋបាលជលផលក្រចេះ និងគណៈកម្មការសហគមន៍នេសាទនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១។ សហគមន៍នេសាទវត្ថុរ្លនៈ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលេខ៦២៨ ប្រក.កសក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ក្រោមការសម្របសម្រួល និងគាំទ្រផ្នែកបច្ចេកទេសពីខណ្ឌរដ្ឋបាលជលផលក្រចេះ។ យោងតាមភាពគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (ដំណាក់កាលទី៣) សមាសភាគទី១ ដែលអនុវត្តដោយខណ្ឌរដ្ឋបាលក្រចេះបានសម្របសម្រួលចុះធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨។ ឆ្លងតាមការធ្វើបច្ចុប្បន្នភាពសមាជិកដែលបានចុះក្នុងបញ្ជីជាផ្លូវការសរុបចំនួន៩៣នាក់ ស្រីចំនួន៦៤ នាក់ ក្នុងនោះគ្រួសារសរុបមានចំនួន៩២ គ្រួសារ។ គណៈកម្មការសហគមន៍នេសាទវត្ថុរ្លនៈមានចំនួន៩នាក់ ស្រីចំនួន២នាក់ និងបានជ្រើសរើសជំនួយការជាស្ត្រីចំនួន២នាក់ដោយបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងបែងចែកតួនាទីនិងភារកិច្ចទទួលខុសត្រូវតាមការស្ម័គ្រចិត្ត ដោយមានឯកភាពគ្នាក្នុងចំណោមសមាជិកគណៈកម្មការទាំងអស់។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនេះជួបប្រទះនូវបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងៈ

- បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី រួមមានការបាត់បង់ទីជម្រកត្រីសម្រាប់ពងកូន មានបទល្មើសនេសាទ (ដូចជាវាយមងជាក្រុម ឆក់ ស្បៃមុង បំពុល) មានការបាត់បង់ពូជត្រីធំៗ និងត្រីកម្រ (ឧទា.ត្រីគល់រាំង ត្រីរាជ ត្រីត្រសក់) មានការបាត់បង់ព្រៃលិចទឹកដោយសារការកាប់រាន និងរលើងឫស បរិមាណត្រីថយចុះ អន្លង់រាក់ដោយសារខ្សាច់កួចចូល និងមានដុះខ្សាច់ច្រើន
- បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋ រួមមានតម្លៃកសិផលនិងបន្លែទាប ប្រជាពលរដ្ឋមានប្រាក់ចំណូលទាប ខ្វះដើមទុនប្រកបរបរ និងខ្វះការបណ្តុះបណ្តាលជំនាញមុខរបរចិញ្ចឹមជីវិត
- បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមានការយល់ដឹងរបស់គណកម្មការសហគមន៍នេសាទពីច្បាប់ជលផលនៅមានកម្រិត កិច្ចសហការពីនគរបាលប៉ុស្តិ៍រដ្ឋបាល និងស្ថាប័នពាក់ព័ន្ធមិនទាន់រលូន ជនល្មើសមិនខ្លាចសហគមន៍ (ដោយសារសហគមន៍នៅខ្វះសមត្ថភាព សម្ភារ និងមធ្យោបាយ) ខ្វះការយល់ដឹងពីបរិស្ថាន និងប្រយោជន៍រួម ខ្វះទូកម៉ាស៊ីន ប្រេង សម្ភារ និងថវិកាសម្រាប់ល្បាត ខ្វះសម្ភាររដ្ឋបាល សហគមន៍នេសាទមិនទាន់មានស្នាក់ការសម្រាប់ប្រតិបត្តការ គណៈកម្មការសហគមន៍នេសាទពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំ សហគមន៍នេសាទនៅតែគិតថាការងារគណៈកម្មការជាការងារបច្ចេកទេសនិងជាតួនាទីរបស់បុរស ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារ ការងារផ្ទះនិងលក់ដូរ និង ការចូលរួមរបស់ស្ត្រីក្នុងកិច្ចប្រជុំមានចំនួនច្រើនតែការសម្រេចចិត្តនៅមានកម្រិត។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក. ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មាន១.១៨២ នាក់ ប្រុស៦១០នាក់ ស្រី៥៧២នាក់ ក្នុងនោះមាន ២៧៦គ្រួសារ ជនជាតិខ្មែរចំនួន១០០%។ ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០%។

ស្ថានភាពប្រជាពលរដ្ឋក្នុងសហគមន៍មានដូចខាងក្រោម៖

- ចំនួនស្ត្រីមេម៉ាយមាន ១៩ នាក់
- ចំនួនបុរសពោះម៉ាយមាន ៣ នាក់
- ចំនួនជនពិការមាន ១១ នាក់
- ចំនួនចាស់ជរាមាន ៣៥ នាក់
- កម្រិតសិក្សារួមមានអ្នកមិនចេះអក្សរមានចំនួន៥៧នាក់ ស្រី៣១នាក់ បឋមសិក្សាចំនួនសរុប១៩៥នាក់ ស្រី ៩៧នាក់ និង មធ្យមសិក្សា ១៩២នាក់ ស្រី ៩៩នាក់។

ខ. មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន ៖

- ធ្វើស្រែចំនួន ១២០ គ្រួសារ ដែលមានទំហំដីសរុបចំនួន ១៦១ ហិចតា
- ធ្វើនេសាទជាលក្ខណៈគ្រួសារចំនួន ១២០ គ្រួសារ
- ធ្វើចំការ (បន្លែ ឈើហូបផ្លែ) ចំនួន ២៥ គ្រួសារ ទំហំដីចំការ ៧៥ហិចតា
- ចិញ្ចឹមសត្វ (មាន់ ទា ជ្រូក គោ ក្របី) ៣០ គ្រួសារ
- លក់ដូរជាអាជីព ១៩ គ្រួសារ
- ធ្វើជាងផ្ទះចំនួន ៥ គ្រួសារ
- ជាងកាត់សក់ អ៊ុតសក់ កាត់ដេរ ០២ គ្រួសារ។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

ក. ទីតាំង

កន្លែងនេសាទសហគមន៍វឌ្ឍនៈជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍វឌ្ឍនៈស្ថិតនៅតាមដងទន្លេមេគង្គ មានទំហំ៦៨១ ហិចតា និងមានកំណត់និយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

<u>មានព្រំប្រទល់</u> ៖

- ខាងកើតទល់នឹងពាក់កណ្ដាលទន្លេមេគង្គ ព្រំប្រទល់ឃុំវឌ្ឍនៈ និងឃុំសំបូរនិងឃុំសណ្ដាន់ ស្រុកសំបូរ ខេត្តក្រចេះ
- ខាងលិចទល់នឹងភូមិវឌ្ឍនៈ ឃុំវឌ្ឍនៈ ស្រុកសំបូរ ខេត្តក្រចេះ
- ខាងត្បូងទល់នឹងកន្លែងនេសាទសហគមន៍អន្លង់ព្រះគោ
- ខាងជើងទល់នឹងកន្លែងនេសាទសហគមន៍អន្លង់តាងួន។

ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ វឌ្ឍនៈ មានវិសាលភាពនៅក្នុងទន្លេមេគង្គ ដែលមានព្រៃលិចទឹកដុះរាយនៅតាមមាត់ច្រាំងទន្លេ និងតាមកោះ។ កន្លែងនេសាទសហគមន៍វឌ្ឍនៈ មានបឹងចំនួន ៣ និងព្រែកចំនួន ៥ គឺ៖

| | | |
|---|---|---|
| - បឹងមន្ទីរពេទ្យ | ទំហំ ១,៥ ហិកតា | មានទឹកពីខែមិថុនា ដល់ ខែតុលា |
| - ព្រែកតាសួង | ទំហំ ៧០០ | មានទឹកពីខែកក្កដា ដល់ ខែតុលា |
| - ព្រែកតាលុន | ទំហំ ១៥០០ម | មានទឹកពីខែសីហា ដល់ ខែកញ្ញា |
| - ព្រែកយាយគ្រួស | ទំហំ ១៥០០ម | មានទឹកពីខែសីហា ដល់ ខែកញ្ញា |
| - ព្រែកសណ្តាន់ | ទំហំ ២០០០ម | មានទឹកពីខែសីហា ដល់ ខែតុលា |
| - ព្រែកយាយលា | ទំហំ ៦០០ម | មានទឹកពីខែសីហា ដល់ ខែកញ្ញា |
| - អន្លង់វត្ត | ទំហំ ០,៣៥ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អន្លង់កំប្រ៉ុក | ទំហំ ០,៤២ ហិកតា | មានទឹកពេញមួយឆ្នាំ។ |

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

អន្លង់វត្ត ទំហំ០,៣៥ហិកតា (បណ្តោយ៧០ ម៉ែត្រ និង ទទឹង៥០ ម៉ែត្រ) និង អន្លង់កំប្រ៉ុក ទំហំ០,៤២ហិកតា (បណ្តោយ៧០ម៉ែត្រ និង ទទឹង ៦០ម៉ែត្រ) ជាតំបន់ដែលមានសក្តានុពលអភិរក្សត្រីមេពូជ តាមការសម្រេចរបស់មហាសន្និបាត។

ឃ. ធនធានជលផល

ឃ.១. ប្រភេទត្រី ៖

ត្រីរៀល ត្រីឆ្លាំង ត្រីកេះ ត្រីកញ្ជុះ ត្រីអាចម៍កុក ត្រីក្អែក ត្រីប៉ាស៊ីអ៊ី ត្រីប៉ាវ៉ាមុខ១ ត្រីប៉ាវ៉ាមុខ២ ត្រីប៉ាកក ត្រីគ្រុំ ត្រីឆ្កិន ត្រីកន្ទ្រប់ ត្រីក្របី ត្រីប្រម៉ា ត្រីគ្រសក់ ត្រីក្រាយ ត្រីក្រម៉ម ត្រីខ្ទឹង ត្រីគល់រាំង ត្រីខ្លា ត្រីរ៉ស់ ត្រីឆ្ដោ ត្រីអណ្តែង ត្រីឆ្លូញ ត្រីចេកទុំ។

ឃ.២. ប្រភេទវារីសត្វ ៖

អន្ទង់ ក្តាម ខ្យង ខ្ចៅ គ្រុំ អណ្តើក កន្ធាយ ពស់ កំពិស កង្កែប គីង្គក់។

ឃ.៣. ព្រៃលិចទឹក និងវារីរុក្ខជាតិ

ដើមរាំ ដើមអណ្តែង ដើមជ្រៃ ដើមគ្រែង ដើមល្វាទឹក រាំងទឹក ដើមក្តុល ព្រីងទឹក ដើមអ៊ុយយ៉ាស់។

## ៤. ការធ្វើនេសាទ

ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៩៣ នាក់ ស្រី ៦៥ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទក្នុងសហគមន៍មានចំនួន៣០ នាក់ ស្រី ១៥ នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិក មកពីក្រៅសហគមន៍មានចំនួន១២០ នាក់។

## ខ. ឧបករណ៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ឧបករណ៍នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | |
| សំណាញ់ | វង់ | ១០ | ១០ | | ក្រឡា២-១៥សម ប្រវែង ៤,៥-៦ម | ក្រឡា២-១៥សម ប្រវែង ៤,៥-៦ម | | មករា ដល់ ធ្នូ |
| មង | ក្បូង ៨០ម | ៩២ | ៩០ | ១២០ | ក្រឡា២,៥-៤ សម | ក្រឡា២,៥-៤ សម | ក្រឡា២,៥-៤ សម | មករា ដល់ ធ្នូ |
| សន្ទូចរនង | សាង ១០០ | ៥ | ៣ | ១៥ | ផ្លែលេខ១២ | ផ្លែលេខ១២ | ផ្លែលេខ១២ | មករា ដល់ ធ្នូ |
| បង្កៃ | ផ្លែ | ២៥០ | ១៥០ | ៣៥០ | ផ្លែលេខ៥ | ផ្លែលេខ៥ | ផ្លែលេខ៥ | ឧសភា ដល់ វិច្ឆិកា |
| បង្កុង | ផ្លែ | ៥០០ | ៣០០ | ១០០០ | ផ្លែលេខ១២ | ផ្លែលេខ១២ | ផ្លែលេខ១២ | ឧសភា ដល់ សីហា |
| លប | គ្រឿង | ២៥ | | ១៥០ | មុខកាត់១,២ម ប្រវែង២ម | | មុខកាត់១,២ ម ប្រវែង២ម | មិថុនា-តុលា |

ម=ម៉ែត្រ ស.ម=សង្ទីម៉ែត្រ

ប្រភេទទូកកាណូត

| ប្រភេទទូកកាណូត | ចំនួន | | | ចំណុះ | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកមានម៉ាស៊ីន | ៥០ ទូក | ៣០ ទូក | ៣០ ទូក | ៣០០ គក្រ | ៣០០គក្រ | ៣០គក្រ | ៩-១៣ សេះ | ៩-១៣ សេះ | ៩-១៨ សេះ |

គ.ក្រ=គីឡូក្រាម

## គ. ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ (គីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៣៧៩,៣០ | ៥៨៦,៨៦ | ៩១៦,១៦ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក.ទស្សនៈវិស័យ

សហគមន៍នេសាទវត្តខ្សាន: មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ សហគមន៍នេសាទមានគោលបំណងរួមដូចខាងក្រោម៖

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ។

គ. គោលបំណងជាក់លាក់

- ការពារ និងដាំព្រៃលិចទឹកជាជម្រកត្រីនៅតាមច្រាំងទន្លេ
- បង្កើនជម្រើសមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ តាមរយៈការចិញ្ចឹមសត្វ ត្រី ដាំបន្លែ អេកូទេសចរ និងមានទីផ្សារសម្រាប់កសិផល
- កាត់បន្ថយបទល្មើសនេសាទ តាមរយៈការផ្សព្វផ្សាយនិងចុះល្បាតដោយមានកិច្ចសហការជាមួយអាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ។

ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍

ឃ.១. ធនធានជលផល និងអេកូទេសចរណ៍

ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំដូចមានក្នុងតារាង៖

| ទីតាំង | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ / ប្រវែង | ចំនួន | |
| នៅតាមដងទន្លេមេគង្គ បឹង និងព្រែកទាំងឡាយ នៅខាងក្រៅអន្លង់អភិរក្សសហគមន៍នេសាទ | មករា ដល់ ធ្នូ | សំណាញ់ | ក្រឡា២-១៥សម ប្រវែង៤,៥-៦ម | ២០វង់ | ៣០០-(១០០/ឆ្នាំ សម្រាប់ការងារផ្សព្វផ្សាយ) |
| | មករា ដល់ ធ្នូ | មង | ក្រឡា២,៥-៤សម | ២៤២ត្បូង | |
| | មករា ដល់ ធ្នូ | សន្ទូចរនង | ផ្លែលេខ១១-១២ | ២៣សាង | |
| | ឧសភា ដល់ វិច្ឆិកា | បង្គៃ | ផ្លែលេខ៥-៧ | ៧៥០ផ្លែ | |
| | ឧសភា ដល់ សីហា | បង្កង | ផ្លែលេខ១២ | ១៨០០ផ្លែ | |
| | មិថុនា-តុលា | លប | មុខកាត់១,២ម ប្រវែង២ម | ១៧៥គ្រឿង | |

ម=ម៉ែត្រ ស.ម=សង្ទីម៉ែត្រ

### ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ ត្រូវបានរៀបចំខាងក្រោម ៖

| ឈ្មោះ / ទីតាំង | ទំហំ ហិកតា | ប្រភេទនៃការ អភិរក្ស | សកម្មភាព | ការប៉ាន់ស្មាន ថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់វត្ត | ០,៣៥ | • ត្រីគ្រប់ប្រភេទ<br>• សត្វទឹកគ្រប់ប្រភេទ<br>• ព្រៃលិចទឹកគ្រប់ប្រភេទ | កំណត់ព្រំប្រទល់កន្លែងអភិរក្ស | ១.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | | | បោះបង្គោល ដាក់ស្លាកសញ្ញាហាមឃាត់ | ១.០០០ | | |
| | | | ផលិតនិងផ្សព្វផ្សាយផែនទីអន្លង់អភិរក្ស | ៥០០ | | |
| អន្លង់កំប្រុំក | ០,៤២ | | ផ្សព្វផ្សាយពីសារៈប្រយោជន៍កន្លែងអភិរក្ស | ១២០ | | |
| | | | • សង់រោងយាម<br>• រៀបចំក្រុមល្បាត<br>• ចុះល្បាតជាប្រចាំ | ៥០០ | | |

### ឃ.១.៣. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំខាងក្រោម ៖

| ឈ្មោះ / ទីតាំង | សកម្មភាព | ចំនួន | ការប៉ាន់ស្មាន ថវិកា(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ទំនប់ដៃខ្លា ព្រំប្រទល់ជាមួយភូមិអន្លង់ព្រះគោ និង ព្រំប្រទល់ជាមួយភូមិតាងួន | បោះបង្គោលព្រំប្រទល់កន្លែងនេសាទ (លើគោក) | ៥ បង្គោល (៥x៣០០) | ១.៥០០ | តុលា ២០១៩ | ធ្នូ ២០១៩ |
| ព្រំប្រទល់ជាមួយភូមិសណ្តាន់ ព្រំប្រទល់ជាមួយភូមិអន្លង់ព្រះគោ និង ព្រំប្រទល់ជាមួយភូមិតាងួន | ដាក់ពោងស្លាកសញ្ញាសំគាល់ព្រំប្រទល់ (ក្នុងទឹក) | ១០ (ពោង១០ x៥០០) | ៥.០០០ | តុលា ២០១៩ | ធ្នូ ២០១៩ |
| មុខវត្តវន្នៈ | រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | ១ ផ្ទាំង | ៣០០ | តុលា២០១៩ | ធ្នូ ២០១៩ |

### ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំខាងក្រោម ៖

| ឈ្មោះ / ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវការពារ | សកម្មភាព | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| នៅតាមច្រាំងទន្លេ មាត់អូរព្រែក និងតាមកោះ | តាមមាត់ទន្លេ និងកោះក្នុងកន្លែងនេសាទសហគមន៍វល្លិនេះ | ព្រៃលិចទឹកដែលត្រូវការពាររួមមានសណ្តាន់ រាំង ឆ្អឹងគ្រី និងប្រភេទព្រៃចម្រុះ | • ប្រជុំផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក<br>• ដាំព្រៃលិចទឹក ៥០០ដើម<br>• ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក និងស្លាកសញ្ញាសម្គាល់ចំនួន ៥<br>• ចុះល្បាតជាប្រចាំ | ៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ

### ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូលត្រូវបានរៀបចំខាងក្រោម ៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមគោ<br>• ចែកពូជគោ<br>• តាមដានត្រួតពិនិត្យ | ពូជក្នុងស្រុក | ៣៥គ្រួសារ (គោមេ១ក្បាល/១គ្រួសារ) | ១៣.១២៥ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសអ្នកទទួល ផល<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ពូជក្នុងស្រុក | ១៥គ្រួសារ (២០ក្បាល/១គ្រួសារ) | ៣.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សួនបន្លែតាមលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសធ្វើសួន បន្លែជាគ្រួសារ<br>• ចែកគ្រាប់ពូជ អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ | បន្លែគ្រប់មុខ | (២៥ គ្រួសារx១០០) | ២.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ (ត្រីឆ្តិន និងត្រីអណ្ដែង) | • ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ<br>• ធ្វើអាងចិញ្ចឹមត្រី<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | អាងស៊ីម៉ង់ត៍ ទំហំ៤ម x ៣ម | ២០ គ្រួសារx ១.០០០ | ២០.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំខាងក្រោម ៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| សាងសង់ផ្លូវពីក្បាលភូមិវឌ្ឍនៈទៅឆ្នាំង ប្រវែង ២.៥០០ម៉ែត្រ | ១ ខ្សែ | ២៥.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ជីកស្រះស្តុកទឹក (៥០មx៥០មx៤ម) នៅចំណុចទួលអាផ្លង់ | ១ កន្លែង | ១៥.៦០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សាងសង់ទំនប់នៅទួលមានជ័យប្រវែង ១៧៧ម៉ែត្រ ទំហំ១២ម៉ែត្រ | ១ ខ្សែ | ៧.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ជីកប្រឡាយ (៧០០ម៉ែត្រ) ពីទំនប់ដៃខ្លាទៅត្បូង | ១ ខ្សែ | ៧.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

ម=ម៉ែត្រ

ឃ.៣. ការគ្រប់គ្រង

ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំខាងក្រោម ៖

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| សហគមន៍នេសាទចុះល្បាតដោយខ្លួនឯង | | ៨ដង/១ខែ (៨ដងx១២ខែx៣x២៥) | ៧.២០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន | | ២ដង/១ខែ (២ដងx១២ខែx៣x២៥) | ១.៨០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ផ្តល់សម្ភារល្បាត (១ ឈុត) | អាវពោង | ១២ អាវ | ១.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | អាវភ្លៀង | ១២ អាវ | | | |
| | គោមបំភ្លឺពាក់ក្បាល | ២ គោម | | | |
| | វិទ្យុទាក់ទង | ២ គ្រឿង | | | |

| | | | | | |
|---|---|---|---|---|---|
| | កែវយឺត | ២ គ្រឿង | | | |
| | ម៉ាស៊ីនថត | ១ គ្រឿង | | | |
| | អង្រឹង | ១២ | | | |
| | តង់គ្របទូក ៤មx៦ម | ១ | | | |
| | សម្ភារត្រួតពិនិត្យទឹក | ១គ្រឿង | | | |
| | ស្លាបចក្រ | ៦គ្រឿង | | | |
| | សោរសម្រាប់ជួសជុលទូក | ១សម្រាប់ | | | |
| | សោរច្រវាក់ចាក់ទូក | ២ | | | |
| | អាវយឺត | ២៤ | | | |
| ទិញទូកស្ទាច់ និងម៉ាស៊ីន | | ២ គ្រឿង | ៣.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ប្រេងសម្រាប់ល្បាត | | ៨០ លីត្រ/ខែx៣៦ខែ | ២.៨៨០ | | |
| សេវាជួសជុលនិងថែទាំទូក និងម៉ាស៊ីន | | ២ដង/ឆ្នាំ (៦ដងx១០០) | ៦០០ | | |
| សាងសង់ទីស្នាក់ការ សហគមន៍នេសាទ | | ១ កន្លែង | ៣.០០០ | តុលា ២០១៩ | ធ្នូ ២០១៩ |

ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ (៣៦ដងx១០) | ៣៦០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ(តំណាងសហគមន៍នេសាទ) | ១ដង/១ខែ (៣៦ដងx១០) | ៣៦០ | | |
| ចូលរួមប្រជុំបណ្តាញសហគមន៍នេសាទ | តាមការអញ្ជើញ | ៥០ | | |
| យុទ្ធនាការហែរក្បួនបំផុសការយល់ដឹងអំពីច្បាប់ជលផល និងសារៈប្រយោជន៍នៃធនធានជលផល (សមាជិកទាំងអស់) | ១ដង/១ឆ្នាំ (៣ដងx៣០០) | ៩០០ | | |
| បណ្តុះបណ្តាលគណកម្មការសហគមន៍នេសាទពីច្បាប់ជលផល | ១លើក/១ឆ្នាំ (៣លើកx២០) | ៦០ | | |
| បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ និងរបាយការណ៍ | | ៦០ | | |
| បណ្តុះបណ្តាលជំនាញរៀបចំផែនការគ្រប់គ្រង | | ៦០ | | |
| បណ្តុះបណ្តាលជំនាញសម្របសម្រួល | | ៦០ | | |
| បណ្តុះបណ្តាលការដោះស្រាយទំនាស់ | | ៦០ | | |
| បណ្តុះបណ្តាលរបៀបគ្រប់គ្រងបញ្ជីចំណូល ចំណាយ | | ៦០ | | |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | ៦០ | | |
| ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | ១លើក | ៥០០ | | |

### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោម៖

| ផែនការ | សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| បង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ២ដង/ឆ្នាំ (៦ដងx២៥) | ១៥០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទ | ១ដង/ឆ្នាំ (៣ដងx២៥) | ៧៥ | | |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | | ៧៥ | | |
| | ផ្សព្វផ្សាយដែននេសាទនិងកន្លែងអភិរក្ស | | ៧៥ | | |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់សមាជិកភាព និងភាគទានប្រចាំឆ្នាំ | ១ដង/ឆ្នាំ (៣ដងx១០) | ៣០ | | |
| | ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ | ១ដង/ឆ្នាំ (៣ដងx២៥) | ៧៥ | | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ (៣ដងx១០០) | ៣០០ | | |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រី ក្នុងសហគមន៍នេសាទ និងការងារផ្ទះ: សមភាពនិងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ (៣ដងx២៥) | ៧៥ | | |

### ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងតាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ១៥០ (៣លើកx៥០) | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មាការសហគមន៍នេសាទ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ៣០ (៣លើកx១០) | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មាការសហគមន៍នេសាទ |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះប្រមូលប្រាក់សមាជិកភាព | កក្កដា ២០១៩ | មិថុនា ២០២២ | ១១,៦៣ | ៥០០ រៀល/នាក់ (៩៣នាក់) |
| ភាគទានប្រចាំឆ្នាំ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | | | ១៣៩,៥០ | ២.០០០ រៀល/គ្រួសារ ក្នុងមួយឆ្នាំ (៩៣នាក់) |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល) | • ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>• សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | | | ១២៨.១១៨,៨៧ | សរសេរគម្រោងចំណាយថវិកា ៥០០ដុល្លារ |
| សរុប | | | | ១២៨.២៧០ | |

### ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ | ផ្សេងៗ |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការសហគមន៍នេសាទ | ១២០ (១២ដងx១០) |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពី ស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការសហគមន៍នេសាទ | ៦០០ (៣ដងx២០០) |

ច. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឲ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលសុំគាំទ្រថវិកានិងជួយរកដៃគូទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ
- ជ្រើសរើសស្ត្រីមេគ្រួសារ ជាសមាជិកចំនួនយ៉ាងតិច៧% ចូលរួមក្នុងសកម្មភាពទ្រទ្រង់ជីវភាពរស់នៅ
- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទចូលរួមយ៉ាងតិច ៤០% ក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាព ទ្រទ្រង់ជីវភាពរស់នៅ និងវារីវប្បកម្ម
- កម្មករគ្មានជំនាញជាស្ត្រីជាសមាជិកសហគមន៍នេសាទ៤០%ចូលរួមសកម្មភាពហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច
- អញ្ជើញស្ត្រីមេគ្រួសារ ស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិចជាសមាជិកសហគមន៍នេសាទ ចូលរួមប្រជុំ និងចូលរួមសកម្មភាពនានា និងចូលជាគណៈកម្មការរបស់សហគមន៍នេសាទ
- ជ្រើសរើសស្ត្រីជាសមាជិកសហគមន៍នេសាទ ៥០% ចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព
- ផ្តល់ឱកាសស្ត្រី៥០%ជាសមាជិកសហគមន៍នេសាទចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព និងទទួលផលប្រយោជន៍ពីគម្រោងក្នុងនោះស្ត្រីជាមេគ្រួសារ៧%
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការចូលរួមក្នុងការសម្រេចចិត្តនានា
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការមិនបោះបង់ចោលការងារ
- រៀបចំការប្រជុំឱ្យសមស្របនឹងពេលវេលារបស់ស្ត្រី ដែលមានលទ្ធភាពចូលរួម

ជំរុញឱ្យមានស្ត្រីយ៉ាងតិច២៥% ជាសមាជិកគណកម្មាការសហគមន៍នេសាទ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍វឌ្ឍនៈរយៈពេល ៣ ឆ្នាំ( កក្កដា ២០១៩- មិថុនា ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | |
| ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ ២ ដង ក្នុង០១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ៣០០ | រដ្ឋបាលជលផល អង្គការដៃគូ សហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ | កំណត់ព្រំប្រទល់កន្លែងអភិរក្ស សហគមន៍នេសាទ | កន្លែងអភិរក្សមានព្រំប្រទល់ច្បាស់លាស់ដោយមានការទទួលស្គាល់ពីស្ថាប័នជំនាញ និងមានផែនទីសម្គាល់អន្លង់អភិរក្ស | ១.០០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | បោះបង្គោលដាក់ស្លាកសញ្ញាហាមឃាត់ | ស្លាកសញ្ញាសម្គាល់កន្លែងអភិរក្សចំនួន០៥ | ១.០០០ | | | | |
| | ផលិត និងផ្សព្វផ្សាយផែនទីកន្លែងអភិរក្ស | ផែនទីចំនួន ២ផ្ទាំងត្រូវបានដាក់នៅកន្លែងអភិរក្ស | ៥០០ | | | | |
| | ផ្សព្វផ្សាយពីសារៈប្រយោជន៍កន្លែងអភិរក្សសហគមន៍នេសាទ | សមាជិកសហគមន៍នេសាទចំនួន៣៥នាក់ ស្រី១០ នាក់ចូលរួម និងយល់ដឹងពីកន្លែងអភិរក្ស | ១២០ | | | | |
| | សង់រោងយាមទំហំ ៤ម x៥ម | រោងយាមចំនួន០១ត្រូវបានសាងសង់នៅកន្លែងអភិរក្ស | ៥០០ | | | | |
| ឃ.១.៣. ផែនការបោះបង្គោលព្រំ | បោះបង្គោលព្រំប្រទល់កន្លែងនេសាទ(លើគោក) | បង្គោលព្រំចំនួន ៥បង្គោលត្រូវបានបោះ | ១.៥០០ | រដ្ឋបាលជលផល អង្គការដៃគូ | តុលា ២០១៩ | ធ្នូ ២០១៩ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | ដាក់ពោងស្លាកសញ្ញាសំគាល់ព្រំប្រទល់ (ក្នុងទឹក) | ពោងស្លាកសញ្ញាសំគាល់ព្រំប្រទល់ចំនួន ១០ ត្រូវបាដាក់ | ៥.០០០ | | តុលា ២០១៩ | ធ្នូ ២០១៩ | |
| | រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | ផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍១ផ្ទាំងត្រូវបានតម្លើង | ៣០០ | | | | |
| ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | ដាំព្រៃលិចទឹកតាមច្រាំងទន្លេ មាត់អូរ និងនៅតាមកោះចាប់ពីដើមភូមិដល់ចុងភូមិ | ព្រៃលិចទឹកដែលត្រូវការពារព្រមទាំងដាំឡើងវិញ រួមមាន ត្រែង រៃ ត្រស់ រាំង ទន្លា | ៥០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | |
| ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល | ចិញ្ចឹមគោជាលក្ខណៈគ្រួសារ | ៣៥ គ្រួសារចេះបច្ចេកទេសចិញ្ចឹមគោ និងអាចលក់រកប្រាក់ចំណូលបន្ថែម | ១៣.១២៥ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ | ១៥ គ្រួសារចេះបច្ចេកទេសចិញ្ចឹមមាន់ និងអាចលក់រកប្រាក់ចំណូលបន្ថែម | ៣.០០០ | | | | |
| | រៀបចំសួនបន្លែតាមលក្ខណៈគ្រួសារ | ២៥ គ្រួសារចេះបច្ចេកទេសដាំបន្លែ និងអាចលក់រកប្រាក់ចំណូលបន្ថែម | ២.៥០០ | | | | |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីអណ្តែង និងត្រីឆ្ពិនក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | សមាជិកសហគមន៍២០គ្រួសារមានជំនាញចិញ្ចឹមត្រី និងអាចរកប្រាក់ចំណូល ធ្វើឱ្យជីវភាពប្រសើរឡើង | ២០.០០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.២.៣. ផែនការ[illegible]សហគមន៍ និង | សាងសង់ផ្លូវពីក្បាលភូមិវត្តខ្នុះទៅឆ្នាំង ប្រវែង ២.៥០០ម៉ែត្រ | ផ្លូវ១ខ្សែប្រវែង ២.៥០០ម៉ែត្រត្រូវបានសាងសង់ និងប្រើជា | ២៥.០០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ហេដ្ឋារចនាសម្ព័ន្ធ | | ប្រយោជន៍រួមសហគមន៍នេសាទ | | សហគមន៍នេសាទ សប្បុរសជន | | | |
| | ជីកស្រះស្តុកទឹក (៥០x៥០x៤) | ស្រះ១ កន្លែងត្រូវបានជីក និងប្រើជាប្រយោជន៍រួមរបស់សហគមន៍នេសាទ | ១៥.៦០០ | | | | |
| | សាងសង់ទំនប់នៅទួលមានជ័យ ប្រវែង ១៧៧ម៉ែត្រ ទំហំ ១២ម៉ែត្រ | ទំនប់១ ខ្សែត្រូវបានសាងសង់ និងប្រើជាប្រយោជន៍រួមរបស់សហគមន៍នេសាទ | ៧.០០០ | | | | |
| | ជីកប្រឡាយ (៧០០ម) ពីទំនប់ដៃខ្លាទៅត្បូង | ប្រឡាយ១ ខ្សែត្រូវបានជីក និងប្រើជាប្រយោជន៍រួមរបស់សហគមន៍នេសាទ | ៧.០០០ | | | | |
| **ឃ.៣. ការងារគ្រប់គ្រង** | | | | | | | |
| ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | សហគមន៍ចុះល្បាតដោយខ្លួនឯង | ៨ដង/១ខែ | ៧.២០០ | រដ្ឋបាលជលផល អង្គការដៃគូ សប្បុរសជន សហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | ២ដង/១ខែ | ១.៨០០ | | | | |
| | ផ្តល់សម្ភារល្បាតដល់ក្រុមល្បាត | ១ឈុត | ១.០០០ | | | | |
| | ទិញទូកស្អាច់ម៉ាស៊ីន | ២គ្រឿង (១តូច ១ធំ) | ៣.០០០ | | | | |
| | ប្រេងសម្រាប់ល្បាត | ៨០លីត្រ/ខែ | ២.៨៨០ | | | | |
| | សេវាជួសជុលនិងថែទាំទូក និងម៉ាស៊ីន | ២ដង/ឆ្នាំ | ៦០០ | | | | |
| | សាងសង់ទីស្នាក់ការសហគមន៍ | ស្នាក់ការចំនួន១ ត្រូវបានសាងសង់ | ៣.០០០ | | កក្កដា ២០១៩ | កញ្ញា ២០១៩ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | ៣៦០ | រដ្ឋបាលជលផល អង្គការដៃគូ សប្បុរសជន សហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ(តំណាងសហគមន៍) | ១ដង/១ខែ | ៣៦០ | | | | |
| | ចូលរួមប្រជុំបណ្តាញសហគមន៍នេសាទ | ចូលរួមតាមការអញ្ជើញ កំណត់ហេតុកិច្ចប្រជុំ | ៥០ | | | | |
| | យុទ្ធនាការហែរក្បួនបំផុសការយល់ដឹងអំពីច្បាប់ជលផល និងសារៈប្រយោជន៍នៃធនធានជលផល (សមាជិកទាំងអស់) | ១លើក/១ឆ្នាំ | ៩០០ | | | | |
| | បណ្តុះបណ្តាលគណៈកម្មការសហគមន៍នេសាទអំពីច្បាប់ជលផល | ១លើក/១ឆ្នាំ | ៦០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ និងរបាយការណ៍ | ១លើក/១ឆ្នាំ | ៦០ | | | | |
| | បណ្តុះបណ្តាលជំនាញរៀបចំផែនការគ្រប់គ្រង | ១លើក/១ឆ្នាំ | ៦០ | | | | |
| | បណ្តុះបណ្តាលជំនាញសម្របសម្រួល | ១លើក/១ឆ្នាំ | ៦០ | | | | |
| | បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | ១លើក/១ឆ្នាំ | ៦០ | | | | |
| | បណ្តុះបណ្តាលរបៀបគ្រប់គ្រងបញ្ជីចំណូល ចំណាយ | ១លើក/១ឆ្នាំ | ៦០ | | | | |
| | បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | ១លើក/១ឆ្នាំ | ៦០ | | | | |
| | ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | ១លើក | ៥០០ | | | | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ២ដង/ឆ្នាំ | ១៥០ | រដ្ឋបាលជលផល អង្គការដៃគូ សប្បុរសជន សហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ១ដង/ឆ្នាំ | ៧៥ | | | | |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | ១ដង/ឆ្នាំ | ៧៥ | | | | |
| | ផ្សព្វផ្សាយដែននេសាទនិងកន្លែងអភិរក្ស | ១ដង/ឆ្នាំ | ៧៥ | | | | |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់សមាជិកភាព និងភាគទានប្រចាំឆ្នាំ | ១ដង/ឆ្នាំ | ៣០ | | | | |
| | ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុទ្ធពាក់ព័ន្ធ | ១ដង/ឆ្នាំ | ៧៥ | | | | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ | ៣០០ | | | | |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរសស្ត្រីក្នុងសហគមន៍នេសាទនិងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ | ៧៥ | | | | |
| ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ១ដង/ឆ្នាំ | ១៥០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ១ដង/ឆ្នាំ | ៣០ | គណៈកម្មការ | | | |
| ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់ | ភាគទានពីសមាជិកសហគមន៍ | សមាជិកសហគមន៍ បានបង់ភាគទានសមាជិកភាព | ១១,៦៣ | សហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | ៥០០ រៀល/នាក់ (៩៣នាក់) |



ឋ

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| អភិវឌ្ឍន៍សហគមន៍ | ភាគទានប្រចាំឆ្នាំ | ១ឆ្នាំម្តង | ១៣៨ | | កក្កដា ២០១៩ | មិថុនា ២០២២ | ២.០០០ រៀល/គ្រួសារ ក្នុងមួយឆ្នាំ(៩៣គ្រួសារ) |
| | ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការដៃគូ) | សហគមន៍នេសាទទទួលបានកញ្ចប់ថវិកាពីប្រភពផ្សេងៗ | ១២៧.៦២០,៣៧ | រដ្ឋបាលជលផល អង្គការដៃគូ | | | |
| ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ៤ដង/ឆ្នាំ | ១២០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិច | ១ដង/ឆ្នាំ | ៦០០ | រដ្ឋបាលជលផល អង្គការដៃគូ | | | |

## តារាងកម្មវិធីការងារប្រចាំឆ្នាំ កក្កដា ២០១៩- មិថុនា ២០២២

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| យ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| យ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | | | | X | | | | | | | X | | | | | X | | | | | | | X | | | | | X | | | | | | | X | |
| យ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| កំណត់ព្រំប្រទល់កន្លែងអភិរក្ស | | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |
| បោះបង្គោលដាក់ស្លាកសញ្ញាហាមឃាត់ | | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |
| ផលិតនិងផ្សព្វផ្សាយផែនទីកន្លែងអភិរក្សសហគមន៍នេសាទ | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| ផ្សព្វផ្សាយពីសារៈប្រយោជន៍កន្លែងអភិរក្សសហគមន៍នេសាទ | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| សង់រោងយាមកន្លែងអភិរក្ស | | | | | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| យ.១.៣. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បោះបង្គោលព្រំប្រទល់កន្លែងនេសាទសហគមន៍(លើគោក) | | | | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាក់ពោងស្លាកសញ្ញាសំគាល់ព្រំប្រទល់ (ក្នុងទឹក) | | | | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | | | | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| **ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាំព្រៃលិចទឹកតាមច្រាំងទន្លេ មាត់អូរ និងនៅតាមកោះចាប់ពីដើមភូមិដល់ចុងភូមិ | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |
| **ឃ.២. ការគាំទ្រជីភាពប្រជាពលរដ្ឋ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| បច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| រៀបចំសួនបន្លែតាមលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| **ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមត្រីអណ្តែង និងត្រីឆ្ពិនក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| **ឃ.២.៣. ផែនការសេវាសហ គមន៍ និងហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សាងសង់ផ្លូវពីក្បាលភូមិវិឌ្ឍនៈទៅឆ្នាំង | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ជីកស្រះស្តុកទឹកនៅចំណុចទួលអាផ្លង់ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់ទំនប់នៅទួលមានជ័យ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ជីកប្រឡាយពីទំនប់ជ្រៃខ្លាទៅត្បូង | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |



tܿ

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| **ឃ.៣. ការងារគ្រប់គ្រង** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចុះល្បាតជាប្រចាំដើម្បីទប់ស្កាត់បទល្មើសនេសាទក្នុងកន្លែងនេសាទសហគមន៍ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ផ្តល់សម្ភារល្បាតដល់ក្រុមល្បាត | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ទិញទូកស្អាច់ និងម៉ាស៊ីន | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រេងសម្រាប់ការងារល្បាត | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សេវាជួសជុលនិងថែទាំទូកនិងម៉ាស៊ីន | | | | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់ទីស្នាក់ការសហគមន៍នេសាទ | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.២. ពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចូលរួមប្រជុំបណ្តាញសហគមន៍នេសាទ | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | |
| យុទ្ធនាការហែរក្បួនបំផុសការយល់ដឹងអំពីច្បាប់ជលផល និងសារៈប្រយោជន៍នៃធនធានជលផល (សមាជិកទាំងអស់) | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| បណ្តុះបណ្តាលគណៈកម្មការសហគមន៍នេសាទអំពីច្បាប់ជលផល | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | |
| បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុនិងរបាយការណ៍ | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | |
| បណ្តុះបណ្តាលជំនាញរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | |
| បណ្តុះបណ្តាលអំពីជំនាញសម្របសម្រួល | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | |
| បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| បណ្តុះបណ្តាលរបៀបគ្រប់គ្រងបញ្ជីចំណូល ចំណាយ | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |
| ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទ ពិសោធន៍ | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X |
| យ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | X | | | | | | | | | X | | | X | | | | | | | | | X | | | X | | | | | | | | | X | | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | |
| ផ្សព្វផ្សាយពីកន្លែងអភិរក្ស | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ផ្សព្វផ្សាយពីការប្រមូលប្រាក់សមាជិកភាព និងភាគទានប្រចាំឆ្នាំ | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | |
| ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុទ្ធពាក់ព័ន្ធ | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរសស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| **ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | X | X | | | | | | | | | | | X | X | | | | | | | | | | | X | X | | | | | | | | | | |
| **ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ភាគទានពីសមាជិកសហគមន៍ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ភាគទានប្រចាំឆ្នាំ | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពី អង្គការជាតិ និងអង្គការដៃគូ) | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពី ស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |

លេខ ...១២ ស.ក.ជ.ស.ប

បានឃើញ និងគោរពជូន

លោកនាយផ្នែករដ្ឋបាលជលផលកំពី

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ.....កើត ខែ.....ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

សំបូរ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៩

នាយសង្កាត់រដ្ឋបាលជលផលសំបូរ

ស៊ុំ ចាន់រ៉ុង

លេខ :.....

បានឃើញ និងគោរពជូន

លោកនាយសង្កាត់រដ្ឋបាលជលសំបូរ

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ.....កើត ខែ.....ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ឃុំវង្សេន: ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៩

មេឃុំវង្សេន:

យុន គីម

សូមគោរពជូន

លោកមេឃុំវង្សេន:

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ.....កើត ខែ.....ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

វង្សេន: ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៩

ប្រធានគណៈកម្មការសហគមន៍នេសាទវង្សេន:

ស៊ុន សង

លេខ : [illegible]

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ"

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ក្រចេះ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៩

ប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ

ទ្រី សុភក្តិ

លេខ : ១៥២ [illegible]

បានឃើញ និងគោរពជូន

លោកប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ក្រចេះ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៩

នាយខណ្ឌរដ្ឋបាលជលផលក្រចេះ

សៀន គិន

លេខ : [illegible]

បានឃើញ និងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

កាំពី ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១៩

ក. នាយផ្នែករដ្ឋបាលជលផលកាំពី

លេខ : ២០[illegible]

បានឃើញ និងឯកភាព

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១៩

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**